# ព្រះរាជក្រឹត្យ

នស/រកត/០៣១៨/៧២៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែង និងឋានៈ ឯកឧត្តម **ឡុង សុភ័ក្រ** ពីទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** ដំឡើងឋានៈឯកឧត្តម **ម៉ក់ ឌុល** ពីទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទៅជាទីប្រឹក្សាមានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា៣ :** តែងតាំងនិងផ្តល់ឋានៈលោកជំទាវ **នង សុម៉ាលីកា** ជាទីប្រឹក្សាឯកឧត្តម **អ៊ឹម សូស្តី** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា៤ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចារស.១៨០៣.២៦៩

លេខ: ២៩០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**